# របាយការណ៍សង្ខេបស្ដីពីការវាយតម្លៃបឋមលើផលប៉ះពាល់នៃ សេចក្ដីព្រាងប្រកាសស្ដីពីលក្ខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការកែប្រែ ការព្យួរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការ ទូរគមនាគមន៍

មកទល់ពេលបច្ចុប្បន្ននេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មិនទាន់មានបទប្បញ្ញត្តិស្ដីពីការកំណត់លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ដែលត្រូវបានផ្សព្វផ្សាយនិងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅឡើយ ការផ្ដល់អាជ្ញាបណ្ណនាពេលកន្លងមកត្រូវបានធ្វើឡើងតាមទម្លាប់និងតាមប្រភេទសេវានីមួយៗប៉ុណ្ណោះ។ អ្នកកាន់អាជ្ញាបណ្ណមានការលំបាកក្នុងការផ្ដល់សេវាថ្មីៗស្របតាមការវិវត្តនៃបច្ចេកវិទ្យា ពីព្រោះដើម្បីផ្ដល់សេវាថ្មីមួយ អ្នកកាន់អាជ្ញាបណ្ណត្រូវស្នើសុំអាជ្ញាបណ្ណថ្មីមួយបន្ថែមទៀត ហើយខ្លឹមសារនៃអាជ្ញាបណ្ណមានលក្ខណៈជាកិច្ចព្រមព្រៀងឬកិច្ចសន្យា ដែលមិនទាន់មានលក្ខណៈជាឧបករណ៍និយ័តកម្មនៅឡើយ។ កម្រៃអាជ្ញាបណ្ណមិនទាន់មានស្តង់ដាកំណត់ជាក់លាក់នៅឡើយដែរ អត្រាកម្រៃអាជ្ញាបណ្ណខ្លះនៅមានកម្រិតខ្ពស់ពេក។ លើសពីនេះទៀត ការអនុវត្តរបស់ប្រតិបត្តិករទូរគមនាគមន៍មួយចំនួននាពេលកន្លងមកបានបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែង និងបង្កឲ្យមានការព្រួយបារម្ភដល់ប្រជាពលរដ្ឋផងដែរអំពីបរិស្ថានសុខភាពនិងសុវត្ថិភាពសាធារណៈ។

សំណើប្រកាសស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍នឹងត្រូវធ្វើឡើងស្របតាមមាត្រា ៥ ចំណុច (ច) និងជំពូកទី១៤ នៃច្បាប់ស្ដីពីទូរគមនាគមន៍។ សំណើប្រកាសមានគោលបំណង (១)-ធានាភាពច្បាស់លាស់លើការធ្វើនិយ័តកម្មលើលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ (២)-ធានាការប្រកួតប្រជែងប្រកបដោយតម្លាភាពនិងស្មើភាពក្នុងវិស័យទូរគមនាគមន៍ (៣)-ជំរុញការវិនិយោគដើម្បីពង្រីកវិសាលភាពនិងពង្រឹងគុណភាពសេវាទូរគមនាគមន៍ (៤)-ការពារផលប្រយោជន៍អ្នកប្រើប្រាស់និងវិនិយោគិនលើវិស័យទូរគមនាគមន៍ និង (៥)-ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននានាដល់សុខភាព សុវត្ថិភាពសាធារណៈ ការការពារនិងអភិរក្សបរិស្ថាន និងការអភិរក្សវប្បធម៌ ដែលបណ្ដាលមកពីការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនិងបណ្ដាញ និងការផ្ដល់សេវាទូរគមនាគមន៍។

ដើម្បីជាមូលដ្ឋានក្នុងការវិភាគនិងប្រៀបធៀប ក្រុមការងារវាយតំលៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តបានជ្រើសរើសជម្រើសពីរយកមកពិភាក្សា៖

ជម្រើសទី១ រក្សាស្ថានភាពដើម ដោយអនុវត្តទៅតាមលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ តែពង្រឹងនូវយន្តការតាមដាននិងត្រួតពិនិត្យ ការសម្របសម្រួល និងការដោះស្រាយផលប៉ះពាល់អវិជ្ជមាននានា

ជម្រើសទី២ សំណើប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ដែលបានរៀបរាប់ខាងលើ។

ផ្អែកតាមការប៉ាន់ស្មានលើបន្ទុកចំណាយនិងផលចំណេញនៃជម្រើសទាំងពីរ ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០២០ គិតក្នុងតម្លៃបច្ចុប្បន្ន (Present Value) ដោយយកអត្រា (Discount Rate) ១០% ក្នុងមួយឆ្នាំ យើងឃើញថា ការចំណាយក្នុងតម្លៃបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលក្នុងជម្រើសទី១ ស្មើនឹង ៩៩០.១៣៩,០៤ (ប្រាំបួនរយកៅសិបពាន់មួយរយសាមសិបប្រាំបួនក្បៀសសូន្យបួន) ដុល្លារអាមេរិក ហើយការចំណាយក្នុងតម្លៃបច្ចុប្បន្នរបស់ធុរកិច្ចក្នុងជម្រើសទី១ ស្មើនឹង ៦.២៤១.៥២៤,១៨ (ប្រាំមួយលានពីររយសែសិបមួយពាន់ប្រាំរយម្ភៃបួនក្បៀសដប់ប្រាំបី) ជាសរុបការចំណាយទាំងពីរនេះស្មើនឹង ៧.២៣១.៦៦៣,២២ (ប្រាំពីរលានពីររយសាបសិបមួយពាន់ប្រាំមួយរយហុកសិបបីក្បៀសម្ភៃពីរ) ដុល្លារអាមេរិក។ ជម្រើសទី១នឹងចូលរួមក្នុងចំណូលសេដ្ឋកិច្ចជាតិចំនួន ៨.៣៥០.១៥៤,៨៧ (ប្រាំបីលានបីរយហាសិបពាន់មួយរយហាសិបបួនក្បៀសប៉ែតសិបប្រាំពីរ) ដុល្លារអាមេរិក។

ការចំណាយក្នុងតម្លៃបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលក្នុងជម្រើសទី២ ស្មើនឹង ៦៨៤.៦៦១,១៥ (ប្រាំមួយរយប៉ែតសិបបួនពាន់ប្រាំមួយរយហុកសិបមួយក្បៀសដប់ប្រាំ) ដុល្លារអាមេរិក ហើយការចំណាយក្នុងតម្លៃបច្ចុប្បន្នរបស់ធុរកិច្ចក្នុងជម្រើសទី២ ស្មើនឹង ៥.៦៤២.៨៩៣,៩៨ (ប្រាំលានប្រាំមួយរយសែសិបពីរពាន់ប្រាំបីរយកៅសិបបីក្បៀសកៅសិបប្រាំបី) ដុល្លារអាមេរិក ជាសរុបការចំណាយទាំងពីរនេះស្មើនឹង ៦.៣២៧.៥៥៥,១៣ (ប្រាំមួយលានបីរយម្ភៃប្រាំពីរពាន់ប្រាំរយហាសិបប្រាំក្បៀសដប់បី) ដុល្លារអាមេរិក។ ជម្រើសទី២នឹងចូលរួមក្នុងចំណូលសេដ្ឋកិច្ចជាតិចំនួន ១០.៨៤៤.៦៨៨,៥៨ (ដប់លានប្រាំបីរយសែសិបបួនពាន់ប្រាំមួយរយប៉ែតសិបប្រាំបីក្បៀសហាសិបប្រាំបី) ដុល្លារអាមេរិក។

បើយើងប្រៀបធៀបទៅលើជម្រើសទាំងពីរ យើងឃើញថា ចំណាយក្នុងជម្រើសទី២តិចជាងចំណាយក្នុងជម្រើសទី១ចំនួន ៩០៤.១០៨,០៩ (ប្រាំបួនរយបួនពាន់មួយរយប្រាំបីក្បៀសសូន្យប្រាំបួន) ដុល្លារអាមេរិក ហើយការចូលរួមក្នុងចំណូលសេដ្ឋកិច្ចជាតិនៃជម្រើសទី២លើសជម្រើសទី១ចំនួន ២.៤៩៤.៥៣៣,៧១ (ពីរលានបួនរយកៅសិបបួនពាន់ប្រាំរយសាមសិបបីក្បៀសចិតសិបមួយ) ដុល្លារអាមេរិក។ ជាសរុបជម្រើសទី២ ផ្តល់នូវផលចំណេញច្រើនជាងជម្រើសទី១ ចំនួន ៣.៣៩៨.៦៤១,៨០ (បីលានបីរយកៅសិបប្រាំបីពាន់ប្រាំមួយរយសែសិបមួយក្បៀសប៉ែតសិប) ដុល្លារសហរដ្ឋអាមេរិក ដោយគិតក្នុងតម្លៃបច្ចុប្បន្ន សរុបពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០។

ផ្អែកលើលទ្ធផលនៃការវិភាគលើបន្ទុកចំណាយនិងផលចំណេញនៃជម្រើសទាំងពីរខាងលើ ឃើញថា យើងគួរជ្រើសរើសយកជម្រើសទី២ (សំណើប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍) ពីព្រោះជម្រើសទី២នេះផ្តល់នូវផលចំណេញច្រើនជាងជម្រើសទី១។

និយ័តករទូរគមនាគមន៍កម្ពុជាជាអង្គភាពដែលមានភារកិច្ចធ្វើនិយ័តកម្មក្នុងវិស័យទូរគមនាគមន៍ ត្រួតពិនិត្យ និងតាមដានការផ្តល់សេវាទូរគមនាគមន៍ស្របតាមបទប្បញ្ញត្តិជាធរមាន។ នៅពេលដែលសំណើប្រកាសនេះចូលជាធរមាន និយ័តករទូរគមនាគមន៍កម្ពុជានឹងរៀបចំនូវសេចក្តីណែនាំលម្អិតដើម្បីអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់។ ដើម្បីឆ្លើយតបឲ្យទាន់ពេលវេលាទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមាន គួរមានការពិនិត្យឡើងវិញបន្ទាប់ពីសំណើប្រកាសនេះត្រូវបានអនុវត្តក្នុងរយៈពេលពីបីទៅប្រាំឆ្នាំ ហើយការពិនិត្យឡើងវិញនេះត្រូវពឹងផ្អែកទៅលើការវាយតម្លៃលើផលប៉ះពាល់ជាក់ស្តែងនៃបទប្បញ្ញត្តិ ដោយមានការសិក្សាស្រាវជ្រាវនិងការពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធ។

# ការវាយតម្លៃបឋមលើផលប៉ះពាល់

| | | |
|---|---|---|
| បញ្ញត្តិកម្ម | ៖ | សេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ |
| ក្រសួង | ៖ | ប្រៃសណីយ៍ និងទូរគមនាគមន៍ |
| លេខយោង | ៖ | បទ ០០០១ |
| កាលបរិច្ឆេទចាប់ផ្តើម | ៖ | ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ |
| កាលបរិច្ឆេទបញ្ចប់ | ៖ | ថ្ងៃទី០៥ ខែ តុលា ឆ្នាំ២០១៦ |

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍គ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមមាត្រា ៥ ចំណុច (ច) និងជំពូកទី១៤ នៃច្បាប់ស្តីពីទូរគមនាគមន៍។ ចំណុចសំខាន់ៗដែលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនិងនីតិវិធីក្នុងប្រកាសនេះមានដូចជា៖

(១) លក្ខខណៈសម្បត្តិនៃអ្នកស្នើសុំ ព្រមទាំងវិសាលភាពនិងគុណភាពសេវា
(២) ប្រភេទលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ
(៣) រយៈពេលមានសុពលភាពរបស់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ
(៤) កម្រៃសម្រាប់ការស្នើសុំនិងកម្រៃប្រចាំឆ្នាំនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ
(៥) មូលហេតុនៃការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ
(៦) សិទ្ធិនិងកាតព្វកិច្ចរបស់ប្រតិបត្តិករទូរគមនាគមន៍និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

## ប្រភេទបញ្ញត្តិកម្ម៖

សូមគូសសញ្ញាក្នុងប្រអប់ឱ្យត្រូវនឹងប្រភេទបញ្ញត្តិកម្មណាមួយ ហើយសូមអធិប្បាយប្រសិនបើ សំណើនោះជាប្រភេទផ្សេងទៀត

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☐ | ☑ | ☐ | ☐ | ☐ |

## ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យៈ

☑ សេដ្ឋកិច្ច ☑ សង្គមកិច្ច ☑ បរិស្ថាន ☑សន្តិសុខ

## ១. ការកំណត់បញ្ហា

### ១.១. បញ្ហាចម្បងដែលបញ្ញត្តិកម្មនេះមានបំណងដោះស្រាយ

មកទល់បច្ចុប្បន្ននេះមិនទាន់មានបទប្បញ្ញត្តិស្តីពីការកំណត់លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណដែលត្រូវបានផ្សព្វផ្សាយនិងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅឡើយ។ ការអនុវត្តលើការផ្តល់អាជ្ញាបណ្ណនាពេលកន្លងមកត្រូវបានធ្វើឡើងតាមទម្លាប់និងតាមប្រភេទសេវានីមួយៗប៉ុណ្ណោះ។ កង្វះនូវទម្រង់ការនិងដំណើរការច្បាស់លាស់ក្នុងការផ្តល់អាជ្ញាបណ្ណនេះ បានបង្កផលលំបាកជាច្រើនដល់អ្នកស្នើសុំអាជ្ញាបណ្ណ ដោយមិនដឹងថាត្រូវដាក់ពាក្យស្នើសុំទៅស្ថាប័នណា ថាតើគួរដាក់ទៅរាជរដ្ឋាភិបាល ឬទៅច្រកចេញចូលតែមួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬដោយផ្ទាល់មកនិយ័តករទូរគមនាគមន៍កម្ពុជា ដើម្បីទទួលបានអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ណាមួយ។

អាជ្ញាបណ្ណនីមួយៗដែលបានផ្តល់នាពេលកន្លងមកនេះតម្រូវសម្រាប់តែសេវាមួយប៉ុណ្ណោះ នេះគឺជាបុព្វហេតុនាំឲ្យមានការរារាំងដល់អ្នកកាន់អាជ្ញាបណ្ណក្នុងការផ្តល់សេវាថ្មីៗស្របតាមការវិវត្តនៃបច្ចេកវិទ្យា ពីព្រោះដើម្បីផ្តល់សេវាថ្មីមួយ អ្នកកាន់អាជ្ញាបណ្ណត្រូវស្នើសុំអាជ្ញាបណ្ណថ្មីមួយបន្ថែមទៀត។

ខ្លឹមសារនៃអាជ្ញាបណ្ណនាពេលកន្លងមកមានលក្ខណៈជាកិច្ចព្រមព្រៀងឬកិច្ចសន្យា ដែលមិនទាន់មានលក្ខណៈជាឧបករណ៍និយ័តកម្មនៅឡើយ។ ទម្រង់អាជ្ញាបណ្ណបែបនេះបានដាក់បន្ទុកទៅលើភាគីចុះហត្ថលេខីទាំងពីរឲ្យទទួលខុសត្រូវក្នុងការអនុវត្ត និងមានការលំបាកដល់ការធ្វើវិសោធនកម្មលើករណីផ្សេងៗដែលតម្រូវ។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាស្ថាប័នរបស់រាជរដ្ឋាភិបាលតំណាងឲ្យអាណាព្យាបាលបច្ចេកទេសក្នុងការគ្រប់គ្រងវិស័យទូរគមនាគមន៍ និងជាអ្នកប្រមូលចំណូលបានមកពីកម្រៃអាជ្ញាបណ្ណ ប៉ុន្តែបច្ចុប្បន្ននេះ កម្រៃអាជ្ញាបណ្ណមិនមានស្តង់ដាកំណត់ជាក់លាក់នៅឡើយ។ ចំណូលពីកម្រៃអាជ្ញាបណ្ណទាំងនោះត្រូវបានគិតទៅតាមភាគរយនៃចំណូលដុលដែលបានមកពីប្រតិបត្តិការសេវាទូរគមនាគមន៍តាមប្រភេទអាជ្ញាបណ្ណនីមួយៗ និងមានអត្រាខុសៗគ្នា។ ក្នុងករណីខ្លះ ប្រភេទអាជ្ញាបណ្ណផ្តល់សេវាប្រហាក់ប្រហែលគ្នា តែមានអត្រាខុសគ្នាខ្លាំង ឧទាហរណ៍ដូចជា សេវាវីអូអាយភី (VoIP) មានអត្រាកម្រៃអាជ្ញាបណ្ណ ២% ៤% ៦% នៃចំណូលដុលទៅតាមរយៈពេលនៃសេវា ប៉ុន្តែសេវាច្រកទូរគមនាគម៍អន្តរជាតិ (ITGW) មានអត្រាកម្រៃអាជ្ញាបណ្ណរហូតដល់ ៥១% នៃចំណូលដុល។ មានអត្រាកម្រៃអាជ្ញាបណ្ណខ្លះនៅមានកម្រឹតខ្ពស់ពេក ឧទាហរណ៍អាជ្ញាបណ្ណសេវាអ៊ីនធឺណិត (ISP) មានអត្រាកម្រៃអាជ្ញាបណ្ណ ១០% នៃចំណូលដុល។ កត្តាទាំងនេះជាបុព្វហេតុធ្វើឲ្យប៉ះពាល់ដល់ការប្រមូលទុនវិនិយោគពីសំណាក់វិនិយោគិន ហើយប៉ះពាល់ដល់ការប្រមូលចំណូលថវិកាជាតិពីវិស័យទូរគមនាគមន៍ផងដែរ។

### ១.២. បញ្ហាពាក់ព័ន្ធផ្សេងៗទៀតដែលបញ្ញត្តិកម្មនេះអាចជួយដោះស្រាយបានផងដែរ

| បញ្ហាសំខាន់ៗ | បទប្បញ្ញត្តិនេះមានបំណងដោះស្រាយ | ភស្តុតាង/ភាពជាក់ស្តែង |
|---|---|---|
| សុខភាពនិងសុវត្ថិភាពសាធារណៈ | មែន | ១) មានប្រតិបត្តិករទូរគមនាគមន៍មួយចំនួនបានធ្វើការសាងសង់និងបើកការដ្ឋានសំណង់របស់ខ្លួនដោយមិនបានធ្វើការបំពាក់ស្លាកសញ្ញាការដ្ឋាន ដែលជាកត្តាមួយអាចធ្វើឲ្យប៉ះពាល់ដល់សុវត្ថិភាពសាធារណៈ។<br><br>២) មានការតវ៉ាពីសំណាក់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការសាងសង់អង់តែនទូរគមនាគមន៍ នៅលើដំបូលផ្ទះឬអគារត្រង់កន្លែងពួកគាត់រស់នៅដោយយកហេតុផលថាវាអាចមានវិទ្យុកម្មនាំឲ្យមានការប៉ះពាល់ដល់សុខភាពរបស់ពួកគាត់នៅក្នុងតំបន់នោះ (ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ មានចំនួន ៤ ករណី)។ |
| ការការពារនិងអភិរក្សបរិស្ថាន | មែន | មានតម្រូវការសាងសង់បណ្តាញទូរគមនាគមន៍នៅតាមទីប្រជុំជន ដងផ្លូវជាតិ និងផ្លូវលំ ដោយកប់ដី ដោយព្យួរលើអាកាស លើកំបូលផ្ទះឬអាគារ និងដោយកប់ក្រោមបាតទន្លេ បឹងបួរ ឬសមុទ្រ ហើយការសាងសង់នេះអាចប៉ះពាល់ដល់បរិស្ថានសង្គម ទីតាំងអភិរក្សបរិស្ថានធម្មជាតិ និងសោភ័ណ្ឌភាពសាធារណៈ បើមិនមានការសិក្សាឲ្យបានត្រឹមត្រូវនិងច្បាស់លាស់ទេ។ |
| សមធម៌យេនឌ័រនិងសង្គម និងការអភិរក្សវប្បធម៌ | មែន | មានមាតិការព័ត៌មានមួយចំនួនដែលបានផ្សព្វផ្សាយនៅក្នុងបណ្តាញបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាចធ្វើឲ្យប៉ះពាល់ដល់ស្ត្រី កុមារ សមធម៌យេនឌ័រនិងសង្គម និងការអភិរក្សវប្បធម៌។ |

| | | |
|---|---|---|
| ការប្រកួតប្រជែង | មែន | ក្នុងចំណោមអ្នកកាន់អាជ្ញាបណ្ណឬប្រតិបត្តិករទូរគមនាគមន៍តាមរយៈការប្រើប្រាស់យន្តការទម្លាក់ថ្លៃសន្ធនាក្នុងបណ្តាញតែមួយទាបជាងថ្លៃដើម ( Predatory Pricing ) យន្តការបិទខ្ទប់បណ្តាញតភ្ជាប់រវាងគ្នា និងយន្តការបូកបញ្ចូលគ្នានិងប្រាតិភោគទុន ( Merge & Acquisition )។ |
| ការប្រមូលព័ត៌មានឬទិន្នន័យ | មែន | បណ្តាប្រតិបត្តិករទូរគមនាគមន៍ស្ទើរតែទាំងអស់ បានផ្តល់របាយការណ៍ស្តីពីទិន្នន័យឬព័ត៌មានស្ថិតិសេវាទូរគមនាគមន៍ យឺតយាវ ក្លែងបន្លំតួលេខ និងមានប្រតិបត្តិករមួយចំនួនមិនព្រមផ្តល់ទាល់តែសោះ។ |
| អនុលោមតាមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត | មែន | កម្ពុជាបានចូលជាសមាជិកពេញសិទ្ធិទី ១៤៨ របស់អង្គការពាណិជ្ជកម្មពិភព លោក (WTO) តាំងថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០០៤ ហើយបានធ្វើការប្តេជ្ញាចិត្តធ្វើកំណែទម្រង់លើវិស័យទូរគមនាគមន៍ រួមមានៈ<br>១) កិច្ចការពារលើការប្រកួតប្រជែង<br>២) ការធានាលើការតភ្ជាប់បណ្តាញ<br>៣) តម្លាភាពនិងយន្តការនៃការប្រកួតប្រជែងក្នុងការផ្តល់សេវាសកល<br>៤) លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណ<br>៥) និយ័តករឯករាជ្យ<br>៦) ការប្រើប្រាស់ធនធានកម្រប្រកបដោយប្រសិទ្ធភាព |

**១.៣. សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធឬប៉ះហាក់ប៉ះហែល**

(១) ច្បាប់ស្តីពីទូរគមនាគមន៍៖ ច្បាប់ស្តីពីទូរគមនាគមន៍ជាបទប្បញ្ញត្តិមូលដ្ឋានដែលចង្អុលបង្ហាញដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងនិយ័តករទូរគមនាគមន៍កម្ពុជា ឲ្យរៀបចំប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ កែសម្រួល ព្យួរ និង ដកហូតអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍គ្រប់ប្រភេទ ច្បាប់នេះមិនបានចែងលម្អិតអំពីលក្ខខណ្ឌនិងនីតិវិធីទាំងនេះទេ។

(២) ច្បាប់ស្តីពីសារពើពន្ធ៖ ច្បាប់ស្តីពីសារពើពន្ធគ្រាន់តែផ្តល់នូវលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌនៃអាជ្ញាបណ្ណទូរគមនាគមន៍ ដើម្បីកំណត់ពីកាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាបណ្ណក្នុងការបង់ពន្ធអាករជូនរដ្ឋតែប៉ុណ្ណោះ ច្បាប់នេះមិនបានចែងអំពីលក្ខខណ្ឌនៃការគិតកម្រៃអាជ្ញាបណ្ណឡើយ។

(៣) ច្បាប់ស្តីពីសម្បទាន៖ ច្បាប់ស្តីពីសម្បទានបានកំណត់អំពីលក្ខខណ្ឌផ្តល់កិច្ចសន្យាសម្បទានពាក់ព័ន្ធនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍មូលដ្ឋាន ប៉ុន្តែមិនបានបង្ហាញអំពីនិយមន័យនិងនីតិវិធីច្បាស់លាស់ពាក់ព័ន្ធនឹងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ទេ ដែលជាហេតុនាំឲ្យមានការអនុវត្តជាន់ការកិច្ចគ្នាក្នុងការផ្តល់អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍រវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬនិយ័តករទូរគមនាគមន៍កម្ពុជា។

(៤) ច្បាប់ស្តីពីក្ស័យធន៖ ច្បាប់ស្តីពីក្ស័យធនបានបើកឱកាសដល់អ្នកកាន់អាជ្ញាបណ្ណមួយចំនួនធ្វើការគេចវេសពីបំណុលនិងកាតព្វកិច្ចពាក់ព័ន្ធនៅពេលក្ស័យធន ឬរកលេសធ្វើជាក្ស័យធនតាមរយៈការដែលមិនចែងជាយន្តការ ឬនីតិវិធីដោះស្រាយបញ្ហានេះមុនការអនុវត្តច្បាប់។

(៥) ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម៖ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មគ្រាន់តែជួយដល់ការចុះបញ្ជីពាណិជ្ជកម្មដើម្បីផ្តល់នូវសិទ្ធិទទួលបានជានីតិបុគ្គលស្របតាមច្បាប់ និងអាចយកមកប្រើប្រាស់សម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ប៉ុណ្ណោះ។

(៦) ច្បាប់វិនិយោគនិងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគ៖ ច្បាប់វិនិយោគនិងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគជួយដល់អ្នកកាន់អាជ្ញាបណ្ណក្នុងការចុះបញ្ជីប្រកាសទុនវិនិយោគ និងទទួលបានការលើកទឹកចិត្តពីរាជរដ្ឋាភិបាល ដូចជាការរួចពន្ធនាំចូលបរិក្ខារទូរគមនាគមន៍ និងពន្ធលើប្រាក់ចំណេញ ។ល។ ប៉ុន្តែមាត្រា ១០ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគបានរារាំងមិនឲ្យមានការកំណត់ថ្លៃសេវាទូរគមនាគមន៍ ដែលជាហេតុនាំឲ្យបណ្តាអ្នកកាន់អាជ្ញាបណ្ណបានប្រព្រឹត្តការប្រកួតប្រជែងមិនស្មោះត្រង់តាមរយៈការកំណត់ថ្លៃសេវាសន្ទនាទូរស័ព្ទចល័តទាបជាងថ្លៃដើម ដើម្បីដណ្តើមអតិថិជនពីគ្នាទៅវិញទៅមក ដែលនាំឲ្យមានការប្រកាសក្ស័យធនរបស់ក្រុមហ៊ុនមួយចំនួន មានការបូកបញ្ចូលគ្នា និងប្រាតិភោគទុន និងធ្វើឲ្យបាត់ចំណូលរដ្ឋ។

(៧) ក្រមរដ្ឋប្បវេណីនិងក្រមព្រហ្មទណ្ឌ៖ ក្រមរដ្ឋប្បវេណីនិងក្រមព្រហ្មទណ្ឌមិនអាចប្រើប្រាស់សម្រាប់ចាត់វិធានការដោះស្រាយវិវាទរបស់អ្នកកាន់អាជ្ញាបណ្ណទូរគមនាគមន៍ទាំងស្រុងបានឡើយ។

**១.៤. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?**

សំណើប្រកាសនេះនឹងមិនមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងទេ តែផ្ទុយទៅវិញនឹងជួយជំរុញឲ្យមានបរិយាកាសការប្រកួតប្រជែងប្រកបដោយភាពស្មោះត្រង់ តម្លាភាព និងស្មើភាព។

## ២. គោលបំណង

សំណើប្រកាសនេះបង្កើតឡើងក្នុងគោលបំណងដូចខាងក្រោម៖

- ធានាភាពច្បាស់លាស់លើការធ្វើនិយ័តកម្មលើលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍
- ធានាការប្រកួតប្រជែងប្រកបដោយតម្លាភាពនិងស្មើភាពក្នុងវិស័យទូរគមនាគមន៍
- ជំរុញការវិនិយោគដើម្បីពង្រីកវិសាលភាពនិងពង្រឹងគុណភាពសេវាទូរគមនាគមន៍
- ការពារផលប្រយោជន៍អ្នកប្រើប្រាស់និងវិនិយោគិនលើវិស័យទូរគមនាគមន៍
- ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននានាដល់សុខភាព សុវត្ថិភាពសាធារណៈ ការការពារនិងអភិរក្សបរិស្ថាន និងការអភិរក្សវប្បធម៌ ដែលបណ្តាលមកពីការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញនិងការផ្តល់សេវាទូរគមនាគមន៍។

## ៣. ជម្រើស

ជម្រើសទី១៖ រក្សាស្ថានភាពដើម (អនុវត្តទៅតាមលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដោយពង្រឹងនូវយន្តការតាមដាននិងត្រួតពិនិត្យ ការសម្របសម្រួល និងការដោះស្រាយផលប៉ះពាល់អវិជ្ជមាននានា)

ជម្រើសទី២៖ សំណើប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាក់ព័ន្ធ និងផលចំណេញ

### ៤.១. ការកំណត់ភាគីពាក់ព័ន្ធនិងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១ | • ការតាមដាននិងត្រួតពិនិត្យលើការអនុវត្តទៅតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាត និងបទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត<br>• ការដោះស្រាយវិវាទប្រតិបត្តិការទូរគមនាគមន៍<br>• ការសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ<br>• ការដោះស្រាយផលប៉ះពាល់ អវិជ្ជមានផ្សេងៗ ដូចជាសុខភាពសាធារណៈ និងបរិស្ថាន ។ល។ | • ការរៀបចំបែបបទស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាត<br>• ការបង់កម្រៃសម្រាប់ការស្នើសុំ<br>• ការដោះស្រាយវិវាទប្រតិបត្តិការទូរគមនាគមន៍<br>• ការសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ<br>• ការដោះស្រាយផលប៉ះពាល់អវិជ្ជមានផ្សេងៗ ដូចជាសុខភាពសាធារណៈនិងបរិស្ថាន ។ល។ |

| | | |
|---|---|---|
| ជម្រើសទី២ | • ការរៀបចំប្រកាស ការវាយតម្លៃលើផលប៉ះពាល់ និងការផ្សព្វផ្សាយប្រកាសនេះ<br>• ការតាមដាននិងត្រួតពិនិត្យលើការអនុវត្តទៅតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាត និងបទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត<br>• ការដោះស្រាយវិវាទប្រតិបត្តិការទូរគមនាគមន៍<br>• ការសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ<br>• ការដោះស្រាយផលប៉ះពាល់អវិជ្ជមានផ្សេងៗ ដូចជាសុខភាពសាធារណៈ និងបរិស្ថាន ។ល។ | • ការរៀបចំបែបបទស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាត<br>• ការបង់កម្រៃសម្រាប់ការស្នើសុំ<br>• ការដោះស្រាយវិវាទប្រតិបត្តិការទូរគមនាគមន៍<br>• ការសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ<br>• ការដោះស្រាយផលប៉ះពាល់អវិជ្ជមានផ្សេងៗ ដូចជាសុខភាពសាធារណៈ និងបរិស្ថាន ។ល។ |

## ៤.២. ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| ជម្រើសទី១ | - ការពង្រីកវិសាលភាពនិងគុណភាពនៃសេវាបានខ្លះ<br>- កំណើននៃការប្រើប្រាស់សេវាបានខ្លះ |
| ជម្រើសទី២ | - ការពង្រីកវិសាលភាពនិងគុណភាពនៃសេវាបានច្រើនជាងជម្រើសទី១<br>- កំណើននៃការប្រើប្រាស់សេវាបានច្រើនជាងជម្រើសទី១ |

## ៤.៣. វិសាលភាពនៃជម្រើសនីមួយៗ

ក) ចំនួនអាជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាត ក្នុងឆ្នាំ២០១៦

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួន កំពុងដំណើរការ | ចំនួន មិនដំណើរការ | ចំនួន សរុប |
|---|---|---|---|---|
| ជម្រើសទី១ | មាត់ច្រកទូរគមនាគមន៍អន្តរជាតិ | ៣ | ០ | ៣ |
| | ទូរស័ព្ទចល័ត (2G, 3G, 4G, LTE) | ៦ | ៥ | ១១ |
| | ទូរស័ព្ទអចល័ត | ៨ | ១ | ៩ |

| | | | | |
|---|---|---|---|---|
| | វីអូអាយភី (VoIP) | ១៨ | ១០ | ២៨ |
| | សេវាអ៊ីនធឺណិត (ISP) | ៣៣ | ១១ | ៤៤ |
| | បណ្តាញខ្សែកាបអុបទិក | ៣ | ០ | ៣ |
| | ខ្សែកាបក្រោមសមុទ្រ | ១ | ២ | ៣ |
| | ផ្កាយរណប | ០ | ១ | ១ |
| | អង់តែន | ១ | ៣ | ៤ |
| | បណ្តាញតម្លៃបន្ថែម | ១ | ០ | ១ |
| | វីសាត (VSAT) | ១ | ១ | ២ |
| | ថូលហ្វ្រី (Toll Free) | ១ | ០ | ១ |
| | សេវា Directory | ១ | ០ | ១ |
| | Position និង Navigation | ០ | ១ | ១ |
| | សរុបចំនួនអាជ្ញាបណ្ណ | ៧៧ | ៣៥ | ១១២ |
| | វិញ្ញាបនបត្រ | ៩៤ | ០ | ៩៤ |
| | លិខិតអនុញ្ញាត | ៣១៣៨ | ០ | ៣១៣៨ |
| ជម្រើសទី២ | ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ | ៧ | ៧ | ១៤ |
| | សេវាទូរគមនាគមន៍ | ៤៨ | ១២ | ៦០ |
| | សរុបចំនួនអាជ្ញាបណ្ណ | ៥៥ | ១៩ | ៧៤ |
| | វិញ្ញាបនបត្រ | ៩៤ | ០ | ៩៤ |
| | លិខិតអនុញ្ញាត | ៣១៣៨ | ០ | ៣១៣៨ |

ខ) ការប៉ាន់ស្មានអំពីចំនួនអាជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០

ជម្រើសទី១៖

| | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| អាជ្ញាបណ្ណ | ១១២ | ១១៨ | ១២៣ | ១២៧ | ១៣០ |
| វិញ្ញាបនបត្រ | ៩៤ | ១០៣ | ១១៣ | ១២៤ | ១៣៦ |
| លិខិតអនុញ្ញាត | ៣១៣៨ | ៣៤៥២ | ៣៧៩៧ | ៤១៧៧ | ៤៥៩៥ |

ជម្រើសទី២៖

| | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| អាជ្ញាបណ្ណ | ៧៤ | ៧៨ | ៨១ | ៨៣ | ៨៥ |
| វិញ្ញាបនបត្រ | ៩៤ | ១០៣ | ១១៣ | ១២៤ | ១៣៦ |
| លិខិតអនុញ្ញាត | ៣១៣៨ | ៣៤៥២ | ៣៧៩៧ | ៤១៧៧ | ៤៥៩៥ |

គ) ការប៉ាន់ស្មានការចំណាយនិងផលចំណេញ (គិតជាដុល្លារសហរដ្ឋអាមេរិក)ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ គិតក្នុងតម្លៃបច្ចុប្បន្ន (Present Value) ដោយយកអត្រា (Discount Rate) ១០% ក្នុងមួយឆ្នាំ

ការចំណាយ៖

| | ជម្រើសទី១ | ជម្រើទី២ | ការកាត់បន្ថយចំណាយ |
|---|---|---|---|
| រាជរដ្ឋាភិបាល | ៩៩០.១៣៩,០៤ | ៦៨៤.៦៦១,១៥ | ៣០៥.៤៧៧,៨៩ |
| ធុរកិច្ច | ៦.២៤១.៥២៤,១៨ | ៥.៦៤២.៨៩៣,៩៨ | ៥៩៨.៦៣០,២០ |
| សរុប | | | ៩០៤.១០៨,០៩ |

ការចូលរួមក្នុងកំណើនសេដ្ឋកិច្ច៖

| ជម្រើសទី១ | ជម្រើសទី២ | កំណើនចំណូល |
|---|---|---|
| ៨.៣៥០.១៥៥,៨៧ | ១០.៨៤៥.៦៨៨,៥៨ | ២.៤៩៥.៥៣៣,៧១ |

ផលចំណេញសរុប៖

៣.៣៩៨.៦៤១,៨០ (បីលានបីរយកៅសិបប្រាំបីពាន់ប្រាំមួយរយសែសិបមួយក្បៀសប៉ែតសិប) ដុល្លារសហរដ្ឋអាមេរិក

## ៥. កិច្ចពិគ្រោះយោបល់

- កិច្ចប្រជុំក្រុមការងារបច្ចេកទេសនីតិកម្មរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ចំនួនបីលើក
- កិច្ចប្រជុំជាមួយប្រតិបត្តិករទូរគមនាគមន៍ចំនួនពីរលើក
- កិច្ចប្រជុំជាមួយសហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ចំនួនមួយលើក និង
- កិច្ចប្រជុំក្រុមការងារវិភាគលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត។

## ៦. សន្និដ្ឋាន

ផ្អែកលើការប៉ាន់ស្មានបឋមលើប្រភេទចំណាយនិងផលចំណេញនៃជម្រើសនីមួយៗ យើងរំពឹងថា ជម្រើសទី២ មានលក្ខណៈល្អប្រសើរជាងជម្រើសទី១ ពីព្រោះជម្រើសទី២ នេះនឹងមានការចំណាយតិចជាង (ទាំងការចំណាយរបស់រាជរដ្ឋាភិបាលនិងការចំណាយរបស់ធុរកិច្ច) និងមានផលចំណេញច្រើនជាងជម្រើសទី១ ។

រាជរដ្ឋាភិបាលនឹងអាចកាត់បន្ថយការចំណាយលើការតាមដាននិងត្រួតពិនិត្យ ការដោះស្រាយវិវាទ និងការដោះស្រាយផលប៉ះពាល់អវិជ្ជមានផ្សេងៗ។ ដូចគ្នាដែរ ការចំណាយរបស់ធុរកិច្ចនឹងមានការថយចុះតាមរយៈi) ការកាត់បន្ថយចំនួនអាជ្ញាបណ្ណរបស់ប្រតិបត្តិករនីមួយៗ (មានន័យថា ប្រតិបត្តិករនឹងអាចប្រើអាជ្ញាបណ្ណតែមួយសម្រាប់សេវាជាច្រើន) ii) ការសម្រួលលើនីតិវិធីនៃការស្នើសុំ iii) កាត់បន្ថយចំនួននៃការសម្របសម្រួលជាមួយស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ iv) ការកាត់បន្ថយការចំណាយលើការដោះស្រាយវិវាទផ្សេងៗ និង v) កាត់បន្ថយការចំណាយលើការដោះស្រាយផលប៉ះពាល់អវិជ្ជមានផ្សេងៗផងដែរ។

ផលចំណេញក្នុងជម្រើសទី២ គឺការបង្កើនទំនុកចិត្តនិងភាពជឿជាក់របស់ប្រតិបត្តិករទូរគមនាគមន៍ក្នុងការវិនិយោគនិងប្រកបអាជីវកម្មនៅកម្ពុជា តាមរយៈការធានាភាពច្បាស់លាស់លើការធ្វើនិយ័តកម្មនិងការប្រកួតប្រជែងដោយសុចរិត ស្មើភាព និងតម្លាភាព ហើយកំណើននៃការប្រើប្រាស់សេវាទូរគមនាគមន៍ ជាពិសេសសេវាអ៊ីនធឺណិតល្បឿនលឿននឹងចូលរួមដល់កំណើនសេដ្ឋកិច្ចជាតិ (តាមឯកសារស្តីពីយុទ្ធសាស្ត្រអ៊ីនធឺណិតល្បឿនលឿន (Broadband Strategies Handbook) បោះពុម្ពផ្សាយក្នុងឆ្នាំ២០១២ របស់លោក Tim Kelly និង លោក Carlo Maria Rossotto ធនាគារពិភពលោកបានសិក្សាឃើញថា កំណើននៃការប្រើប្រាស់អ៊ីនធឺណិតល្បឿនលឿនចំនួន ១០% នឹងធ្វើឲ្យមានកំណើនសេដ្ឋកិច្ច ១,៣៨%)។

តើចាំបាច់ត្រូវធ្វើការវាយតម្លៃពេញលេញ (RIS) ដែរឬទេ?

☐ ចាំបាច់

☑ មិនចាំបាច់

ហេតុផលដែលមិនចាំបាច់ធ្វើការវាយតម្លៃពេញលេញ (RIS) លើសេចក្តីព្រាងប្រកាសនេះគឺ ដោយពិនិត្យឃើញថា សេចក្តីព្រាងប្រកាសនេះមិនមានផលប៉ះពាល់អវិជ្ជមាននៃបន្ទុកចំណាយនិងផលចំណេញទេ ផ្ទុយទៅ

វិញ វានឹងក្លាយជាលិខិតបទដ្ឋានគតិយុត្តមួយសម្រាប់ជាមូលដ្ឋានក្នុងការធ្វើនិយ័តកម្មអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ កាត់បន្ថយការចំណាយ ផ្តល់ភាពងាយស្រួលដល់ប្រតិបត្តិករ និងជួយទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននានាដល់សុខភាពនិងសុវត្ថិភាពសាធារណៈ ការការពារនិងអភិរក្សបរិស្ថាន និងការអភិរក្សវប្បធម៌ ដែលបណ្តាលមកពីការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ និងការផ្តល់សេវាទូរគមនាគមន៍។

## ៧. ការអនុវត្ត និងការតាមដានត្រួតពិនិត្យ

### ៧.១.តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការដាក់ឱ្យអនុវត្ត?

និយ័តករទូរគមនាគមន៍កម្ពុជាជាអង្គភាពដែលមានភារកិច្ចធ្វើនិយ័តកម្មក្នុងវិស័យទូរគមនាគមន៍ ត្រួតពិនិត្យ និងតាមដានការផ្តល់សេវាទូរគមនាគមន៍ស្របតាមបទប្បញ្ញត្តិជាធរមាន។ អង្គភាពនេះមាន
នាយកដ្ឋានជំនាញជាសេនាធិការក្នុងការអនុវត្តការងារនេះឲ្យមានតម្លាភាពនិងប្រសិទ្ធភាព។
និយ័តករទូរគមនាគមន៍កម្ពុជានឹងរៀបចំផងដែរនូវសេចក្តីណែនាំលម្អិតស្តីពីការអនុវត្ត
នៅពេលដែលសំណើប្រកាស នេះចូលជាធរមាន។

### ៧.២. តើគួរធ្វើការពិនិត្យតាមដានបញ្ញត្តិកម្មនេះឡើងវិញ ក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានដាក់ឱ្យអនុវត្តដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ ឬតាមដានយ៉ាងដូចម្តេច?

ដោយហេតុថា បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមានការរីកចម្រើននិងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដូច្នេះដើម្បីឆ្លើយតបឲ្យទាន់ពេលវេលានិងសមស្របទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យានេះ យើងគួរពិនិត្យឡើងវិញជារឿយៗនូវបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យា។ បទប្បញ្ញត្តិដែលបានស្នើឡើងនេះក៏ដូចគ្នាដែរគួរមានការពិនិត្យឡើងវិញបន្ទាប់ពីត្រូវបានអនុវត្តក្នុងរយៈពេលពីបីទៅប្រាំឆ្នាំ។ ការពិនិត្យឡើងវិញនេះនឹងត្រូវផ្អែកទៅលើការវាយតម្លៃលើផលប៉ះពាល់ជាក់ស្តែងនៃបទប្បញ្ញត្តិ ដោយមានការសិក្សាស្រាវជ្រាវនិងការពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធ។

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ | ទំនាក់ទំនង |
|---|---|---|---|---|---|
| រៀបចំដោយ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | លោក នាង ម៉ៅ | ប្រធាន | | | ០១៦ ៨៤០ ៦២០ |
| | លោក ជាង សុកក្រ | អនុប្រធាន | | | ០៧៧ ៨៤៤ ៥៤៤ |
| | លោក សំ សិទ្ធិសេរី | សមាជិក | | | ០១២ ៥០៩ ៣៨៣ |
| | ឯកឧត្តម អ៊ឹម វុត្ថា | សមាជិក | | | ០១២ ៨១០ ៧៨៦ |
| ផ្តល់យោបល់ដោយ ក្រុម RIA របស់ ECOSOCC៖ | ឯ.ឧ ប៊ិច សុខា | អ្នកគ្រប់គ្រងគម្រោង | | | ០១២ ៦៩៨ ៩៩៩ |
| | លោកជំទាវ ស៊ាង សុផល្លា | ប្រធានក្រុម២ | | | ០១២ ៦៦៥ ២០១ |
| | លោក ហេង វិជ្ជា | សមាជិក | | | ០១២ ៨៨៨ ៩២២ |
| | លោក គង់ វីរៈ | សមាជិក | | | ០៨៩ ៨៩៩ ៥៨៤ |
| ជំនួយការ | លោក រ៉ុម ផល្លីស | បុគ្គលិករដ្ឋបាល | | | ០៧៨ ២៣៥ ០៧៨ |

# ឧបសម្ព័ន្ធ
# ការប៉ាន់ស្មានលើការចំណាយនិងផលចំណេញ

១) ជម្រើសទី១

ក) ការចំណាយរបស់រដ្ឋាភិបាល

| ល.រ | ប្រភេទចំណាយ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ |
|---|---|---|---|---|---|---|
| ១ | ការតាមដាននិងត្រួតពិនិត្យលើការអនុវត្តទៅតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាត និង បទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត | ១១១.២០០ | ១២០.៤០០ | ១២៩.៦០០ | ១៣៩.២០០ | ១៤៩.២០០ |
| ២ | ការដោះស្រាយវិវាទប្រតិបត្តិការទូរគមនាគមន៍ | ២៣.៥០០ | ២៥.៥០០ | ២៨.០០០ | ៣០.៥០០ | ៣៣.០០០ |
| ៣ | ការសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ | ០ | ៦០០ | ៦០០ | ៤០០ | ៤០០ |
| ៤ | ការដោះស្រាយផលប៉ះពាល់អវិជ្ជមានផ្សេងៗ | ៧២.០០០ | ៧៧.៦០០ | ៨២.៤០០ | ៨៧.២០០ | ៩២.០០០ |
| សរុប | | ២០៦.៧០០ | ២២៤.១០០ | ២៤០.៦០០ | ២៥៧.៣០០ | ២៤៧.៦០០ |

តម្លៃបច្ចុប្បន្ន (Present Value) ដោយគិតអត្រា ១០% ក្នុងមួយឆ្នាំ

| អត្រា | ០,១០ | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ០ | ១ | ២ | ៣ | ៤ | សរុប |
| ចំណាយ | ២០៦.៧០០ | ២២៤.១០០ | ២៤០.៦០០ | ២៥៧.៣០០ | ២៤៧.៦០០ | |
| តម្លៃបច្ចុប្បន្ន | ២០៦.៧០០ | ២០៣.៧២៧,២៧ | ១៩៨.៨៤២,៩៨ | ១៩៣.៣១៣,៣០ | ១៨៧.៥៥៥,៤៩ | ៩៩០.១៣៩,០៤ |

ខ) ការចំណាយរបស់ធុរកិច្ច

| ល.រ | ប្រភេទចំណាយ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំបែបបទស្នើសុំអាជ្ញាបណ្ណ | ០,០០ | ៧២.០០០ | ៦០.០០០ | ៤៨.០០០ | ៣៦.០០០ |
| ២ | ការរៀបចំបែបបទស្នើសុំវិញ្ញាបនបត្រ | ០,០០ | ៤.៥០០ | ៥.០០០ | ៥.៥០០ | ៦.០០០ |
| ៣ | ការរៀបចំបែបបទស្នើសុំលិខិតអនុញ្ញាត | ៦២៧.៦០០ | ៦៩០.៤០០ | ៧៥៩.៤០០ | ៨៣៥.៤០០ | ៩១៩.០០០ |
| ៤ | ការបង់កម្រៃសម្រាប់ការស្នើសុំអាជ្ញាបណ្ណ | ០,០០ | ១៨.០០០ | ១៥.០០០ | ១២.០០០ | ៩.០០០ |
| ៥ | ការបង់កម្រៃសម្រាប់ការស្នើសុំវិញ្ញាបនបត្រ | ០,០០ | ១១.៧០០ | ១៣.០០០ | ១៤.៣០០ | ១៥.៦០០ |
| ៦ | ការបង់កម្រៃសម្រាប់ការស្នើសុំលិខិតអនុញ្ញាត | ១៥៦.៩០០ | ១៧២.៦០០ | ១៨៩.៨៥០ | ២០៨.៨៥០ | ៦០០ |
| ៧ | ការដោះស្រាយវិវាទប្រតិបត្តិការទូរគមនាគមន៍ | ៩៤.០០០ | ១០២.០០០ | ១១២.០០០ | ១២២.០០០ | ១៣២.០០០ |
| ៨ | ការសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ | ០,០០ | ១៥.០០០ | ១៥.០០០ | ១០.០០០ | ១០.០០០ |
| ៩ | ការដោះស្រាយផលប៉ះពាល់អវិជ្ជមានផ្សេងៗ | ៣៦០.០០០ | ៣៨៨.០០០ | ៤១២.០០០ | ៤៣៦.០០០ | ៤៦០.០០០ |
| សរុប | | ១.២៣៨.៥០០ | ១.៤៧៤.២០០ | ១.៥៨១.២៥០ | ១.៦៩២.០៥០ | ១.៥៨៨.២០០ |

តម្លៃបច្ចុប្បន្ន ( Present Value ) ដោយគិតអត្រា ១០% ក្នុងមួយឆ្នាំ

| អត្រា | ០,១០ | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ០ | ១ | ២ | ៣ | ៤ | សរុប |
| ចំណាយ | ១.២៣៨.៥០០ | ១.៤៧៤.២០០ | ១.៥៨១.២៥០ | ១.៦៩២.០៥០ | ១.៥៨៨.២០០ | |
| តម្លៃបច្ចុប្បន្ន | ១.២៣៨.៥០០ | ១.៣៤០.១៨១,៨២ | ១.៣០៦.៨១៨,១៨ | ១.២៧១.២៦២,២១ | ១.០៨៤.៧៦១,៩៧ | ៦.២៤១.៥២៤,១៨ |

គ ) ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច

| ល.រ. | ប្រភេទនៃផលចំណេញ | ឆ្នាំទី០ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ |
|---|---|---|---|---|---|---|
| ១ | ភាគរយនៃវិសាលភាពនៃសេវាអ៊ីនធឺណិតល្បឿនលឿន | ៤០០,០០% | ៤៧,២០% | ៥៥,៧០% | ៦៥,៧២% | ៧៧,៥៥% |
| ២ | ភាគរយនៃការប្រើប្រាស់សេវាអ៊ីនធឺណិតល្បឿនលឿន | ២០,០០% | ២៦,០០% | ៣៣,៨០% | ៤៣,៩៤% | ៥៧,១២% |
| ៣ | កំណើននៃការប្រើប្រាស់សេវាអ៊ីនធឺណិតល្បឿនលឿន | ៥.០០% | ៦,០០% | ៧,៨០% | ១០,១៤% | ១៣,១៨% |
| **ការចូលរួមរបស់បទប្បញ្ញត្តិនេះក្នុងកំណើនសេដ្ឋកិច្ចជាតិ** | | **១,២៤៥,៤៥០.០០** | **១.៤៩៤.៥៤០,០០** | **១,៩៤២.៩២០,០០** | **២.៥២៥.៧៧២,៦០** | **៣.២៨៣.៥០៤,៣៨** |

## ២ ) ជម្រើសទី២

## ក ) ការចំណាយរបស់រដ្ឋាភិបាល

| ល.រ | ប្រភេទចំណាយ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំប្រកាស ការវាយតម្លៃលើផលប៉ះពាល់ និងការផ្សព្វផ្សាយប្រកាស | ១២.០០០ | ០,០០ | ០,០០ | ០,០០ | ០,០០ |
| ២ | ការតាមដាននិងត្រួតពិនិត្យលើការអនុវត្តទៅតាម | ៩៦.០០០ | ១០៤.៤០០ | ១១២.៨០០ | ១២១.៦០០ | ១៣១.២០០ |

| | | | | | | |
|---|---|---|---|---|---|---|
| | លក្ខខណ្ឌនៃអាជ្ញាបណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាត និងបទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត | | | | | |
| ៣ | ការដោះស្រាយវិវាទប្រតិបត្តិការទូរគមនាគមន៍ | ៤.៥០០ | ៤.៥០០ | ៥.០០០ | ៥.៥០០ | ៦.០០០ |
| ៤ | ការសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ | ០,០០ | ២០០ | ២០០ | ២០០ | ២០០ |
| ៥ | ការដោះស្រាយផលប៉ះពាល់អវិជ្ជមានផ្សេងៗ | ៣៨.៤០០ | ៤១.៦០០ | ៤៤.៨០០ | ៤៨.៨០០ | ៥២.៨០០ |
| សរុប | | ១៥០.៩០០,០០ | ១៥០.៧០០,០០ | ១៦២.៨០០,០០ | ១៧៦.១០០,០០ | ១៩០.២០០,០០ |

តម្លៃបច្ចុប្បន្ន ( Present Value ) ដោយគិតអត្រា ១០% ក្នុងមួយឆ្នាំ

| អត្រា | ០.១០ | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ០ | ១ | ២ | ៣ | ៤ | **សរុប** |
| ចំណាយ | ១៥០.៩០០,០០ | ១៥០.៧០០,០០ | ១៦២.៨០០,០០ | ១៧៦.១០០,០០ | ១៩០.២០០,០០ | |
| **តម្លៃបច្ចុប្បន្ន** | ១៥០.៩០០,០០ | ១៣៧.០០០,០០ | ១៣៤.៥៤៥,៤៥ | ១៣២.៣០៦,៥៤ | ១២៩.៩០៩,១៦ | **៦៨៤.៦៦១,១៥** |

ខ ) ការចំណាយរបស់ធុរកិច្ច

| ល.រ | ប្រភេទចំណាយ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំបែបបទស្នើសុំអាជ្ញាបណ្ណ | ៧៤.០០០ | ៤០.០០០ | ៣០.០០០ | ២០.០០០ | ២០.០០០ |
| ២ | ការរៀបចំបែបបទស្នើសុំវិញ្ញាបនបត្រ | ៤៧.០០០ | ៤.៥០០ | ៥.០០០ | ៥.៥០០ | ៦.០០០ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | ការរៀបចំបែបបទស្នើសុំលិខិតអនុញ្ញាត | ៦២៧.៦០០ | ៦៩០.៤០០០ | ៧៥៩.៤០០ | ៨៣៥.៤០០ | ៩១៩.០០០ |
| ៤ | ការបង់កម្រៃសម្រាប់ការស្នើសុំអាជ្ញាបណ្ណ | ២២២.០០០ | ១២.០០០ | ៩.០០០ | ៦.០០០ | ៦.០០០ |
| ៥ | ការបង់កម្រៃសម្រាប់ការស្នើសុំវិញ្ញាបនបត្រ | ១២២.២០០ | ១១.៧០០ | ១៣.០០០ | ១៤.៣០០ | ១៥.៦០០ |
| ៦ | ការបង់កម្រៃសម្រាប់ការស្នើសុំលិខិតអនុញ្ញាត | ២០០.០០០ | ២០០.០០០ | ២០០.០០០ | ២០០.០០០ | ២០០.០០០ |
| ៧ | ការដោះស្រាយវិវាទប្រតិបត្តិការទូរគមនាគមន៍ | ១៨.០០០ | ១៨.០០០ | ២០.០០០ | ២២.០០០ | ២៤.០០០ |
| ៨ | ការសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ | ០,០០ | ៥.០០០ | ៥.០០០ | ៥.០០០ | ៥.០០០ |
| ៩ | ការដោះស្រាយផលប៉ះពាល់អវិជ្ជមានផ្សេងៗ | ១៩២.០០០ | ២០៨.០០០ | ២២៤.០០០ | ២២៤.០០០ | ២៦៤.០០០ |
| សរុប | | ១.៥០២.៨០០,០០ | ១.១៨៩.៦០០,០០ | ១.២៦៥.៤០០,០០ | ១.៣៥២.២០០,០០ | ១.៤៥៩.៦០០,០០ |

តម្លៃបច្ចុប្បន្ន (Present Value) ដោយគិតអត្រា ១0% ក្នុងមួយឆ្នាំ

| អត្រា | ០.១០ | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ០ | ១ | ២ | ៣ | ៤ | សរុប |
| ចំណាយ | ១.៥០២.៨០០,០០ | ១.១៨៩.៦០០,០០ | ១.២៦៥.៤០០,០០ | ១.៣៥២.២០០,០០ | ១.៤៥៩.៦០០,០០ | |
| តម្លៃបច្ចុប្បន្ន | ១.៥០២.៨០០,០០ | ១.០៨១.៤៥៤,៥៥ | ១.០៤៥.៧៨៥,៥២ | ១.០១៥.៩២៧,៨៧ | ៩៩៦.៩២៦,៤៤ | **៥.៦៤២.៨៩៣,៩៨** |

គ) ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច

| ល.រ. | ប្រភេទនៃផលចំណេញ | ឆ្នាំទី០ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ |
|---|---|---|---|---|---|---|
| ១ | ភាគរយនៃវិសាលភាពនៃសេវាអ៊ីនធឺណិតល្បឿនលឿន | ៤០,០០% | ៤៨,៤០% | ៥៨,៥៦% | ៧០,៨៦% | ៨៥,៧៤% |
| ២ | ភាគរយនៃការប្រើប្រាស់សេវាអ៊ីនធឺណិតល្បឿនលឿន | ២០,០០% | ២៧,៤០% | ៣៧,៥៤% | ៥១,៤៣% | ៧០,៤៦% |
| ៣ | កំណើននៃការប្រើប្រាស់សេវាអ៊ីនធឺណិតល្បឿនលឿន | ៥,០០% | ៧,៤០% | ១០,១៤% | ១៣,៨៦% | ១៩,០៣% |
| **ការចូលរួមរបស់បទប្បញ្ញត្តិនេះក្នុងកំណើនសេដ្ឋកិច្ចជាតិ** | | **១.២៤៥.៤៥០,០០** | **១.៨៤៣.២៦៦,០០** | **២.៥២៥.២៧៤,៤២** | **៣.៤៥៩.៦២៥,៩៦** | **៤.៧៣៩.៦៨៧,៥៦** |

តម្លៃបច្ចុប្បន្ន (Present Value) ដោយគិតអត្រា ១០% ក្នុងមួយឆ្នាំ

| អត្រា | ០.១០ | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ០ | ១ | ២ | ៣ | ៤ | សរុប |
| ចំណាយ | ១.២៤៥.៤៥០,០០ | ១.៨៤៣.២៦៦,០០ | ២.៥២៥.២៧៤,៤២ | ៣.៤៥៩.៦២៥,៩៦ | ៤.៧៣៩.៦៨៧,៥៦ | |
| តម្លៃបច្ចុប្បន្ន | ១.២៤៥.៤៥០,០០ | ១.៦៧៥.៦៩៦.៣៦ | ២.០៨៧.០០៣,៦៥ | ២.៥៩៩.២៦៨,១៩ | ៣.២៣៧.២៧០,៣៨ | ១០.៨៤៤.៦៨៨,៥៨ |